មន្ទីរសារការីភ្នំពេញ
PHNOM PENH NOTARY PUBLIC

# ការចេញផ្សាយរបស់មន្ទីរសារការីភ្នំពេញ

(លេខ ០២ ប្រចាំ ខែសីហា ឆ្នាំ២០១៦ - © រក្សាសិទ្ធិគ្រប់យ៉ាង)



ដោយសារការី **ស៊ុន តុលា** ដែលមានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកសារការីពីមហាវិទ្យាល័យច្បាប់ **Jean Moulin Lyon 3** នៃប្រទេសបារាំង និងជាសហប្រធានមន្ទីរសារការីភ្នំពេញ។

# វិចារណកថាស្តីពី "ពន្ធប្រថាប់ត្រា"

ប្រកាសថ្មីមួយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ២៧៣ សហវ.ប្រ.ក. ចុះថ្ងៃ **ទី១៧ ខែមីនា ឆ្នាំ២០១៦** ស្តីពី ការបង់ពន្ធប្រថាប់ត្រា បានក្លាយជាចំណាប់អារម្មណ៍មួយដ៏សំខាន់សម្រាប់មជ្ឈដ្ឋានអ្នកអនុវត្តច្បាប់ ក៏ដូចជាប្រជាពលរដ្ឋទូទៅផងដែរ។

មុននឹងបរិយាយអំពី**ពន្ធប្រថាប់ត្រា**នេះ ដំបូងយើងគួរយល់ថាអ្វីទៅដែលហៅថា «**ពន្ធ**»?

**ពន្ធ** គឺជាកាតព្វកិច្ចបង់ជាប្រាក់ ដែលត្រូវបានដាក់ជាបន្ទុកដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយ សម្រាប់ការចំណាយលើសេវាសាធារណៈ ការសម្រេចគោលការណ៍សេដ្ឋកិច្ច និងសង្គម ដែលត្រូវបានកំណត់ដោយអំណាចសាធារណៈ។ ដូចនេះ ដើម្បីធានាថាសេវារដ្ឋបាល និងសន្តិសុខសង្គម នឹងប្រព្រឹត្តទៅបានល្អ ពលរដ្ឋគ្រប់រូបត្រូវមានកាតព្វកិច្ចក្នុងការរួមចំណែកលើការចំណាយដូចរៀបរាប់ខាងលើ តាមរយៈការបង់ពន្ធនេះឯង។

**ពន្ធ** មានច្រើនទម្រង់ ហើយត្រូវបានបង្កើតឡើងតាមរយៈបទបញ្ញត្តិផ្សេងៗ។ ជាក់ស្តែង ពន្ធប្រថាប់ត្រា ដែលជាទម្រង់មួយនៃពន្ធ ត្រូវបាននិម្មិតឡើងដោយច្បាប់ស្តីពី "**ការបង្កើតពន្ធប្រថាប់ត្រា**" ចុះថ្ងៃទី០១ **ខែកុម្ភៈ ឆ្នាំ១៩៩១** នាសម័យរដ្ឋកម្ពុជា ហើយបានវិវត្តជាច្រើនសារចាប់តាំងពីការកកើតនេះ។ ដើម្បីជាបច្ច័យក្នុងការយល់ដឹង ពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រា យើងចាំបាច់ត្រូវសិក្សាជាបន្តបន្ទាប់ អំពី «ការកកើត និងការវិវត្តរបស់ពន្ធប្រថាប់ត្រា» នៅក្នុង**ជំពូកទី១** និងអំពី «កាអនុវត្តពន្ធប្រថាប់ត្រា» នាពេលបច្ចុប្បន្ន នៅក្នុង**ជំពូកទី២**។

ក៏ប៉ុន្តែ តាមរយៈវិចារណកថានេះ យើងនឹងលើកយកមកសិក្សាត្រឹមតែជំពូកទី១ ស្តីពី «ការកកើត និងការវិវត្តរបស់ពន្ធប្រថាប់ត្រា» តែប៉ុណ្ណោះ ហើយយើងនឹងលើកយក**ជំពូកទី២** មកបរិយាយនាឱកាសក្រោយ។

## អំពីមន្ទីរសារការីភ្នំពេញ

មន្ទីរសារការីភ្នំពេញត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៣៨ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ហើយផ្តល់សេវាកម្មផ្នែកច្បាប់ ជាអាទិ៍៖

- ការតាក់តែងកិច្ចសន្យានានា
- ការធ្វើមរតកសាសន៍
- ការបញ្ជាក់ហត្ថលេខា និងសេចក្តីចម្លងតាមច្បាប់ដើម
- ការផ្តល់ប្រឹក្សាផ្នែកច្បាប់ទូទៅ

**ព័ត៌មានបន្ថែម** សូមទាក់ទង៖

- មកទីស្នាក់ការ នៅអគារកាណាឌីយ៉ា ជាន់ទី១២ កែងផ្លូវព្រះអង្គឌួង និងមហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
- ឬតាមរយៈទូរស័ព្ទលេខ ០២៣ ៤៣១ ៧៨៩ ឬតាមរយៈអ៊ីម៉ែល info@ppnp.com.kh

# ជំពូកទី ១
# ការកកើត និងការវិវត្តរបស់ពន្ធប្រថាប់ត្រា

ការសិក្សាស៊ីជម្រៅ បានបង្ហាញឲ្យឃើញថាវិសាលភាពរបស់ពន្ធនេះត្រូវបានធ្វើការកែប្រែច្រើនលើកច្រើនសារ តាំងពីពេលកកើតរហូតមកដល់បច្ចុប្បន្ននេះ។ ដូចនេះ ដើម្បីធ្វើឱ្យយើងអាចយល់ច្បាស់អំពីការវិវត្តទាំងនេះ យើងចាំបាច់ត្រូវរំឭកដោយត្រួសៗអំពីបម្រែបម្រួលរបស់ពន្ធប្រថាប់ត្រាដូចតទៅ ៖

## ផ្នែកទី ១ ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១

ច្បាប់ឆ្នាំ១៩៩១ នេះ បានបង្កើតឱ្យមានពន្ធប្រថាប់ត្រាលើប្រតិបត្តការណ៍ផ្ទេរកម្មសិទ្ធិតាមរយៈការលក់ទិញ លើចលនវត្ថុ និងអចលនវត្ថុ ដូចជា៖

- ផ្ទះ និង ដីសង់លំនៅដ្ឋាន ៦ ភាគរយ
- រថយន្តគ្រប់ប្រភេទ ៤ ភាគរយ
- ម៉ូតូគ្រប់ប្រភេទ ២ ភាគរយ
- ទូក កាណូត កប៉ាល់ សាឡង់ ២ ភាគរយ

ច្បាប់នេះកំណត់ច្បាស់លាស់អំពីអត្រាភាគរយនៃពន្ធដែលត្រូវបង់ ប៉ុន្តែមិនបានបញ្ជាក់ថាតើប្រតិបត្តការណ៍រវាងបុគ្គលណាខ្លះ ដែលត្រូវស្ថិតនៅក្រោមដែនអនុវត្តនៃច្បាប់នេះ។ ដូចនេះ យើងគួរអាចធ្វើការសន្និដ្ឋានថាច្បាប់ឆ្នាំ១៩៩១ អនុវត្តទៅលើគ្រប់ប្រតិបត្តការណ៍ផ្ទេរកម្មសិទ្ធិដែលមានកម្មវត្ថុដូចរៀបរាប់ពីខាងលើ រវាងគ្រប់បុគ្គលសាធារណៈ និងបុគ្គលឯកជន។

នាពេលក្រោយមកទៀត អត្រាភាគរយ និងវត្ថុ ក៏ដូចជាប្រតិបត្តការណ៍ដែលត្រូវជាប់ពន្ធប្រថាប់ត្រាត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥។

## ផ្នែកទី ២ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

ច្បាប់ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ បានកំណត់អំពីបទបញ្ញត្តិផ្សេងៗជាច្រើន ហើយចំណុចដែលនិយាយអំពីពន្ធប្រថាប់ត្រាមានចែង ចាប់ពី**មាត្រា ៤០** រហូតដល់**មាត្រា ៤៥** នៃច្បាប់នេះ។

ច្បាប់នេះធ្វើការកែប្រែចំនុចមួយចំនួន ពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រា ជាពិសេសមាត្រា ៤០ ដែលបានធ្វើការផ្លាស់ប្តូរ និងបន្ថែមយ៉ាងដូច្នេះថា៖

-ពន្ធប្រថាប់ត្រា ត្រូវកំណត់តាមអត្រាសមាមាត្រ **៤ %** ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬ ការផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ ក្រោមរូបភាពជា ការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគទុនក្នុងក្រុមហ៊ុន។ ត្រង់ចំនុចនេះយើងសង្កេតឃើញថា អត្រាពន្ធនៃការផ្ទេរសិទ្ធិលើអចលនទ្រព្យត្រូវបានកាត់បន្ថយចំនួន ២% (ពី ៦% នៃច្បាប់ឆ្នាំ១៩៩១ មកត្រឹម ៤% ចាប់ពីការដាក់ឱ្យអនុវត្តច្បាប់ឆ្នាំ ១៩៩៥ នេះ) ។

-ពន្ធប្រថាប់ត្រា ត្រូវកំណត់តាមអត្រាសមាមាត្រ **៤%** ចំពោះការផ្ទេរកម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូនផ្សេងៗ ។

-ពន្ធប្រថាប់ត្រាក៏នឹងត្រូវបង់ផងដែរ ចំពោះប្រតិបត្តការណ៍គតិយុត្តដូចខាងក្រោម ៖

| | |
|---|---|
| ១- លិខិតស្តីពីការបង្កើតក្រុមហ៊ុន | ១០០០០០ រៀល |
| ២- លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា | ១០០០០០ រៀល |
| ៣- លិខិតស្តីពីការរំសាយក្រុមហ៊ុន | ១០០០០០ រៀល |
| ៤- កិច្ចសន្យាផ្គត់ផ្គង់សេវាសម្ភារទំនិញដល់អង្គការសាធារណៈ | ១០០០០០ រៀល |

ច្បាប់នេះ ត្រូវបានយកមកអនុវត្តជាបន្តបន្ទាប់រហូតត្រូវបានធ្វើការកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលបានពង្រីកវិសាលភាពនៃពន្ធប្រថាប់ត្រា ដូចមានកំណត់នៅក្នុងជំពូកទី៣ ផ្នែកទី ១ នៃច្បាប់ឆ្នាំ២០១៣ នេះ។

## ផ្នែកទី ៣ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

មាត្រា ១២ នៃច្បាប់លេខ ន.ស.រកម.១២១២.០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ បានធ្វើ**ការកែប្រែអត្រាពន្ធ**ដែលមានចែងក្នុង**មាត្រា ៤០** នៃច្បាប់ឆ្នាំ**១៩៩៥** ខាងលើ ហើយអត្រាសមាមាត្រនៃពន្ធប្រថាប់ត្រាត្រូវកំណត់ដូចតទៅ ៖

- **៤ %** នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ/និង សិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬជាដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។
- **៤ %** នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន និង យានយន្តគ្រប់ប្រភេទ។
- **0,១ %** នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។
- **0,១ %** នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវាដែលប្រើប្រាស់ថវិការដ្ឋ។

- **១ ០០០ ០០០ (មួយលាន) រៀល** ចំពោះលិខិតមានលក្ខណៈគតិយុត្ត ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា លិខិតស្តីពីការបិទក្រុមហ៊ុន។

ដោយឡែក **មាត្រា១៣** នៃច្បាប់ដដែលនេះចែងថា ពន្ធប្រថាប់ត្រាត្រូវលើកលែង និងអនុគ្រោះដូចតទៅៈ

- ការទទួលកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល ត្រូវបានលើកលែងពន្ធប្រថាប់ត្រា។
- ការទទួលកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យពីញាតិត្រូវបានអនុគ្រោះឲ្យដកចេញពីតម្លៃគិតពន្ធប្រថាប់ត្រា ចំនួន ៖
    - **២០០ ០០០ ០០០ (ពីររយលាន) រៀល** ចំពោះសន្តតិកម្ម
    - **១០០ ០០០ ០០០ (មួយរយលាន) រៀល** ចំពោះប្រទានកម្ម

ប៉ុន្មានខែបន្ទាប់ពីការអនុម័តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ពោលគឺនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ ប្រកាសមួយទៀតស្តីពីពន្ធប្រថាប់ត្រាត្រូវបានដាក់ឲ្យប្រើប្រាស់ ។

## ផ្នែកទី ៤ ប្រកាសស្តីពី "ការប្រមូលពន្ធប្រថាប់ត្រា" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣

ប្រកាសលេខ៧៣៥ សហវ. ប្រក. អពដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ ស្តីពី "ការប្រមូលពន្ធប្រថាប់ត្រា" ដែលត្រូវបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ថាពន្ធប្រថាប់ត្រាត្រូវប្រមូលចំពោះប្រតិបត្តការណ៍ផ្សេងៗដូចជា ៖

- ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និង ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬ យានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវាដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្តិ ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និង លិខិតស្តីពីការបិទក្រុមហ៊ុន ។

ជាងពីរឆ្នាំក្រោយមក ពោលគឺនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ប្រកាសថ្មីមួយទៀតស្តីពីការប្រមូលពន្ធប្រថាប់ត្រានេះ ត្រូវបានដាក់ឲ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រកាសនេះមានអានុភាពអនុវត្តភ្លាមៗ ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ តទៅ។ ហើយតាមរយៈប្រការ ១០ នៃប្រកាសនេះ ខ្លឹមសារទាំងស្រុងរបស់ប្រកាសចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ ត្រូវបានដាក់ឲ្យនិរាករណ៍។

## ផ្នែកទី ៥  ប្រកាសស្តីពី "ការប្រមូលពន្ធប្រថាប់ត្រា" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

យើងត្រូវដឹងថាការពិតទៅ ប្រកាសថ្មីនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងយន្តការណ៍ថ្មីៗរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការលើកលែងពន្ធមួយចំនួន។ យន្តការណ៍ទាំងនោះត្រូវបានស្តែងឡើងតាមរយៈ៖

- សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ រវាងឪពុកម្តាយបង្កើត និងកូនបង្កើត រវាងប្តី និង ប្រពន្ធ និងរវាងយាយតាបង្កើត និងចៅបង្កើត។
- សេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រាប់ត្រាលើការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និង ជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេស។
- លិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការដោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី។
- លិខិតលេខ ១៩៧ សជណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំគោលការណ៍បន្ថែមលើការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិរវាងឪពុក-ម្តាយ បង្កើត និងកូនបង្កើត រវាងប្តីនិងប្រពន្ធ។

ប្រកាសចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ជាវិធានចុងក្រោយគេពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រាដែលត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់។ ប្រកាសនេះអនុញ្ញាតឱ្យធ្វើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើអចលនទ្រព្យ ដោយពុំមានការបង់ពន្ធប្រថាប់ត្រា ក្នុងករណីផ្ទេរកម្មសិទ្ធិ៖ រវាងឪពុកម្តាយបង្កើត និងកូនបង្កើត រវាងប្តី និងប្រពន្ធ រវាងយាយតាបង្កើត និងចៅបង្កើត ជាដើម។ ល។

ប្រតិបត្តការណ៍មួយចំនួនផ្សេងទៀតក៏នឹងត្រូវលើកលែងពន្ធប្រថាប់ត្រាផងដែរ ហើយចំនុចទាំងនេះយើងនឹងលើកយកមកនិយាយនៅក្នុង**ជំពូកទី២** ដែលនឹងត្រូវចេញផ្សាយនាពេលឆាប់ៗខាងមុខនេះ។

*សូមថ្លែងអំណរគុណដល់ក្រុមការងាររបស់មន្ទីរសារការីភ្នំពេញ ជាពិសេស លោក កាន់ សុទ្ធប៉ូលីន និងលោក ស៊ុន ដានី ចំពោះការអានឡើងវិញ ការផ្តល់យោបល់ និង ការជួយពិនិត្យកំហុសអក្ខរាវិរុទ្ធ ក៏ដូចជាជំនួយបច្ចេកទេសផ្សេងៗ ក្នុងការរៀបចំការចេញផ្សាយនេះ។*

**នៅមានបន្តទៀត!**